**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង អប់រំ យុវជន និង កីឡា**

# សេចក្តីប្រកាសព័ត៌មាន

នៅថ្ងៃទី ១៤ ខែកុម្ភៈ ឆ្នាំ២០១២ វេលាម៉ោង ៨:៣០ នាទី ព្រឹក នៅមន្ទីរអប់រំ យុវជន និងកីឡាខេត្តបន្ទាយមានជ័យ មានប្រារព្ធពិធីប្រគល់ទោចក្រយានយន្តជូនដល់ខេត្តគោលដៅទាំង ៦ ក្រោមអធិបតីភាព **ឯកឧត្តម អ៊ឹម សេធី** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ និងឯកឧត្តមអគ្គរដ្ឋទូត **Jean-Francois Cautain** ប្រធានសហភាពអឺរ៉ុប ប្រចាំប្រទេសកម្ពុជា ព្រមទាំងមានការអញ្ជើញចូលរួមពីមន្ត្រីរាជការ ដៃគូអភិវឌ្ឍវិស័យអប់រំ សហភាពអឺរ៉ុប ស្ថានទូតស៊ុយអែត និងអង្គការយូនីសេហ្វ គរុសិស្ស និងសិស្សានុសិស្ស ក្នុងខេត្តបន្ទាយមានជ័យទាំងមូល ដែលមានចំនួនសរុប ៣៤២ នាក់ ។

កម្មវិធីនេះបានរៀបចំឡើង ដើម្បីឆ្លើយតបនឹងចំណុចដៅនៃផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នានាឆ្នាំ ២០១៥ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៩-២០១៣ គោលដៅអភិវឌ្ឍសហស្សវត្សកម្ពុជា និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាលកម្ពុជា ដែលក្រសួងអប់រំ យុវជន និងកីឡា បានកំណត់គោលនយោបាយធំៗ ៣ ដើម្បីធានាបាននូវសមធម៌នៃការផ្តល់សេវាអប់រំ ការផ្តល់ការអប់រំប្រកបដោយគុណភាព និងប្រសិទ្ធភាព និងការអភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាពដើម្បីធ្វើវិមជ្ឈការ។

ជាមួយនេះដែរ ក្រសួងបានកំណត់កម្មវិធីសាលាកុមារមេត្រី ដែលជាសកម្មភាពសំខាន់ ជំរុញការអនុវត្តការងារចាប់តាំងពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិ ពិសេសគឺការធ្វើឲ្យសម្រេចតាមសមាសភាគទាំង៦ ក្នុងនោះក្រសួងបានបង្កើតក្រុមបំប៉ននិងពិនិត្យតាមដានតាមថ្នាក់ក្រុង ស្រុក ខណ្ឌ (DTMT) ដើម្បីចុះជួយដល់នាយកសាលារៀន គ្រូបង្រៀនលើការងារគ្រប់គ្រង ដឹកនាំ និងការងារបច្ចេកទេសរៀន និងបង្រៀន បន្ទាប់ពីទទួលបានការបំប៉ន។

អាស័យដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៧ ២៥៣ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
Email: crsmeys@camnet.com.kh Web Site: www.moeys.gov.kh

លើសពីនេះ ដើម្បីឲ្យការអនុវត្តកម្មវិធីសាលាកុមារមេត្រីប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព ក្រសួងបានជាមួយសហភាពអឺរ៉ុប ស្ថានទូតស៊ុយអែត និងអង្គការយូនីសេហ្វ ដោយបានផ្តល់ទោចក្រយានយន្តចំនួន ១២១ គ្រឿង ជូនដល់ខេត្តគោលដៅទាំង ៦ រួមមានខេត្តបន្ទាយមានជ័យ ព្រះវិហារ កំពត រតនគីរី ប៉ៃលិន និងខេត្តមណ្ឌលគីរី ក្នុងគោលបំណងជំរុញការចុះជួយសាលារៀនរបស់ក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ក្រុង ស្រុក ខណ្ឌ ប្រកបដោយប្រសិទ្ធភាព និងទាន់ពេល ជាពិសេសគឺធានាបាននូវការអនុវត្តនិងការគោរពពេលម៉ោងសិក្សាឲ្យបានត្រឹមត្រូវជាក់លាក់តាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា សំដៅបន្ថយបានអត្រាត្រួតថ្នាក់នៅបឋមសិក្សា និងឈានទៅសម្រេចចំណុចដៅសំខាន់ៗក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ។

## ខេត្តគោលដៅទាំង ៦ ទទួលបានម៉ូតូ ដូចមានខាងក្រោម៖

| ល.រ | ខេត្ត | ចំនួនម៉ូតូផ្តល់ឲ្យមន្ទីរអយក ខេត្ត | ចំនួន DTMTs | ចំនួនស្រុក | ចំនួនម៉ូតូផ្តល់ឲ្យស្រុក | សរុបចំនួន |
|---|---|---|---|---|---|---|
| ១ | រតនគីរី | ១ | ១៥០ | ៩ | ២៤ | **២៥** |
| ២ | មណ្ឌលគីរី | ១ | ៩៣ | ៥ | ១២ | **១៣** |
| ៣ | ព្រះវិហារ | ២ | ១៧១ | ៨ | ២៦ | **២៨** |
| ៤ | បន្ទាយមានជ័យ | ១ | ២៣៥ | ៩ | ២៤ | **២៥** |
| ៥ | ប៉ៃលិន | ១ | ៥៩ | ២ | ៥ | **៦** |
| ៦ | កំពត | ២ | ១៨៧ | ៨ | ២២ | **២៤** |
| | សរុប | ៨ | ៨៩៥ | ៤១ | ១១៣ | **១២១** |

រាជធានីភ្នំពេញថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១២